# ការជជែកជាមួយនឹង អ៊ីសាបេឡា អំពីសេចក្ដីសញ្ញា

*អ៊ីសាបេឡា មកពី អាឡាជូឡា កូស្ដា រីកា យើងបាន សួរនាងនូវសំណួរមួយចំនួនអំពីអត្ថន័យនៃការរក្សា សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់នាង ។*





**សូមប្រាប់យើងអំពីប្អូន ។**

ខ្ញុំមានអាយុ ១៣ ឆ្នាំ ។ ខ្ញុំចូលចិត្តលេងបាល់ទាត់ ចំអិនអាហារ កាត់ដេរ ហែលទឹក និង បម្រើអ្នកដទៃ ។ ក្ដីស្រមៃរបស់ខ្ញុំគឺចង់ធ្វើជាពេទ្យសត្វ ព្រោះខ្ញុំចូលចិត្តជួយសត្វ ។ អាហារ ដែលខ្ញុំចូលចិត្តគឺ ស្ប៉ាហ្គេតទី និងភីហ្សា ហើយពណ៌ដែលខ្ញុំចូលចិត្តគឺពណ៌ស្វាយ ។



**តើអ្នករក្សាសេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹករបស់អ្នកដោយរបៀបណា ?**

ខ្ញុំប្រែចិត្ត និងទទួលពិធីសាក្រាម៉ង់រាល់សប្ដាហ៍ ។ ខ្ញុំមានការហៅបម្រើក្នុងថ្នាក់យុវនារី របស់ខ្ញុំ ហើយខ្ញុំព្យាយាមធ្វើវាយ៉ាងយកចិត្តទុកដាក់ ។ ខ្ញុំក៏រក្សាសេចក្ដីសញ្ញារបស់ខ្ញុំ ដោយការបម្រើអ្នកដទៃផងដែរ ។



**តើអ្នកធ្វើអ្វីដើម្បីបម្រើអ្នកដទៃ ?**

ខ្ញុំចូលចិត្តជួយគ្រួសាររបស់ខ្ញុំ ។ ខ្ញុំតែងតែលេងជាមួយបងប្អូនជីដូនមួយអាយុបីឆ្នាំ របស់ខ្ញុំឈ្មោះ លីណា ខណៈពេលដែលឪពុកម្ដាយរបស់នាងធ្វើការ ។ ខ្ញុំចូលចិត្ត ជួយលោកតាលោកយាយរបស់ខ្ញុំនៅពេលពួកគាត់ចង់ឲ្យខ្ញុំជួយ ។ ខ្ញុំក៏ជួយមិត្តរួម ថ្នាក់ខ្ញុំត្រៀមប្រឡងភាសាបារាំងនៅសាលាផងដែរ ។





**សូមប្រាប់ខ្ញុំបន្ថែមទៀតអំពីការហៅបម្រើរបស់ប្អូន ។**

ខ្ញុំជាទីប្រឹក្សាទីមួយនៅក្នុងថ្នាក់យុវនារីរបស់ខ្ញុំ ។ ភារកិច្ចរបស់ខ្ញុំរួមមានការផ្ដល់ការងារ បម្រើដល់យុវនារី ។ នេះមានន័យថាជួយពួកគេនូវអ្វីក៏ដោយដែលពួកគេត្រូវការ ។ ខ្ញុំ ចូលរួមក្នុងថ្នាក់ និងសកម្មភាពនានា ហើយខ្ញុំព្យាយាមធ្វើជាមិត្តភក្ដិនឹងក្មេងស្រីផ្សេង ទៀតក្នុងថ្នាក់របស់ខ្ញុំដែលមិនមក ។



**តើអ្នកនឹងផ្ដល់ដំបូន្មានអ្វីដល់នរណាម្នាក់អំពីការហៅបម្រើដំបូងរបស់ពួកគេ ?**

ខ្ញុំនឹងប្រាប់ពួកគេថាមិនបាច់ភ័យទេ ។ ការហៅបម្រើគ្រាន់តែជារបៀបមួយដែលអ្នក អាចជួយកិច្ចការរបស់ព្រះវរបិតាសួគ៌ប៉ុណ្ណោះ ។ របៀបដ៏ល្អបំផុតក្នុងការជួយអ្នកដទៃគឺ តាមរយៈគំរូរបស់អ្នក ! ●

រូបភាពគំនូរដោយ